# អង្គការបណ្តាញសង្គ្រោះកុមារកម្ពុជា

## សេចក្តីសង្ខេប

១-ចំណេងជើង នៃ ការសង្ខេបអត្ថបទស្នាដៃរបស់អង្គការ **CSCN** ។

២-សេសក្តីផ្តើម ។

៣-គោលបំណងដែលចង់បាន ។

៤-វិធីសាស្រ្ត ៖

ក-ការចាប់ដំបូង ។

ខ-ការឧបត្ថម្ភគាំទ្រ ។

៥-លទ្ធផល ។

៦-ការសន្និដ្ឋាន

១-ចំណងជើងអត្ថបទសង្ខេបស្នាដៃរ ៖

## គ្រួសារអ្នកជំងឺរបស់អង្គការ CSCN មានជីវភាពរស់នៅប្រសើរឡើង

## សេចក្តីផ្តើម

អង្គការបណ្តាញសង្គ្រោះកុមារកម្ពុជាគឺជាអង្គការមិនមែនរដ្ឋាភិបាលហើយបានអនុវត្តមកដល់ពេលនេះនូវគំរោងថែទាំសុខភាពអ្នកជំងឺអេដស៏តាមផ្ទះដោយផ្តោតទៅលើសមាហរ័ណកម្មការថែទាំនិងការបង្ការ និង ការកាត់បន្ថយ និង ការឆ្លើយតបទៅនឹងការជះឥទ្ធិពលមេរោគអេដស៏ជំងឺអេដស៏ ។ អង្គការបណ្តាញសង្គ្រោះកុមារកម្ពុជាមានការិយាល័យ

កណ្តាលរបស់ខ្លួលនៅទីរួមខេត្តពោធិ៍សាត់ចំងាយ ប្រហែល ២០០គ.ម.ខាងលិច ក្រុង ភ្នំពេញ, រដ្ឋធានីនៃព្រះរាជាណាចក្រកម្ពុជា ហើយបាន ទទួលនូវការគាំទ្រមូលនិធិពី អង្គការសម្ព័ន្ធខ្មែរប្រយុទ្ធនឹងជំងឺអេដស៍ **(KHANA)** និង អង្គការសុខភាពគ្រួសារ អន្តរជាតិ **(FHI)** ។ អង្គការបណាញសង្គ្រោះកុមារកម្ពុជាកំពុងថៃទាំអ្នកជំងឺចំនួន ៧១៤នាក់ និង កុមារកំព្រា និង ងាយរង្គ្រោះចំនួន ១៤២៩នាក់ ក្នុង១៩ឃុំ ៣ស្រុក និង ២ខេត្ត គឺះ ខេត្តពោធិ៍សាត់ និង ខេត្តបន្ទាយមានជ័យ ហើយទទួលបានការគាំទ្រ ស្បៀងមួយផ្នែកធំ ពីអង្គការស្បៀងអាហារ ពិភពលោក **(WFP)** ។

# គោលបំណងដែលចង់បាន

## ចូលរួមជាមួយគោលដៅថ្នាក់ជាតិៈ

ក-កាត់បន្ថយការចំលងថ្មីនៃមេរោគអេដស៍ ។

ខ-ធ្វើអោយគុណភាពជីវិតរបស់អ្នកជំងឺអេដស៍ និង កុមារកំព្រានិងងាយរងគ្រោះ និងក្រុមគោលដៅដែលប្រឈោមមុខនឹងគ្រោះថ្នាក់បំផុត ។

គ-សម្រាលបន្ទុកសង្គមសេដ្ឋកិច្ចមកលើ បុគ្គល, គ្រួសារ, សហគមន៍ និងសង្គម ។

# វិធីសាស្ត្រ




Her dilapidated shelter

**ការចាប់ផ្តើមដំបូង :**

អ្នកស្រី **ផាន ផល** កាលនោះ មាន អាយុ៣០ឆ្នាំ ជាស្ត្រីមេមាយមានផ្ទុក នូវមេរោគអេដស៍ ហើយ ទទួលបន្ទុក ចិញ្ចឹមកូន២នាក់ទៀត ផង។ អ្នកស្រី មានទីលំនៅ .៧. ភូមិក្រពើរោរិ៍ ឃុំស្នាមព្រះ ស្រុកបាកាន ខេត្ត ពោធិ៍សាត់។ អ្នកស្រីរស់នៅក្នុងខ្ទមមួយដែលទ្រុឌទ្រោម,មានការងារធ្វើមិនទៀងទាត់, អស់សង្ឃឹម, សុខភាពមិនអំណោយផល, និងហ៊ុំព័ទ្ធដោយការរើសអើងនៅក្នុងសហគមន៍ មុនពេលចូលក្នុងក្រុមថែទាំ CSCN នៅឆ្នាំ២០០៥, ប៉ុន្តែអ្នកស្រីមានការតាំងចិត្តយ៉ាងខ្លាំងក្នុងការពុះពារការលំបាកសព្វបែបយ៉ាង ដើម្បីខ្លួនគាត់ផ្ទាល់និងការអភិ វឌ្ឍន៍សេដ្ឋកិច្ចគ្រួសាររបស់អ្នកស្រី។



Positive Community Contribution



New Shelter

# ការឧបត្ថម្ភគាំទ្រ

CSCNរហូតមកទល់សព្វថ្ងៃនេះបានផ្តល់ការគាំទ្រមួយចំនួនដែលមិនអាចកាត់ផ្តាច់បានពីកម្រិតជីវភាពរស់នៅហូបឆ្អែតល្មមនាពេលបច្ចុប្បន្ននេះរបស់អ្នកស្រី ។ ការឧបត្ថម្ភគាំទ្រមានដូចជាការគាំទ្រផ្លូវកាយផ្លូចិត្ត ដែលរួមមានៈ ការផ្តល់ប្រឹក្សា និង សេវាសុខភាពសមស្រប, ការអប់រំសហគមន៍, ការសាងសង់ និង ការជួសជុលជម្រក, ការផ្តល់ស្បៀងអាហារ, ការគាំទ្រសុខមាលភាពសង្គម, ការឧបត្ថម្ភ



Receiving mobile care



Food Support

សម្លៀកបំពាក់ និង សម្ភារៈសិក្សា, ការផ្តល់កម្ចីខ្នាតតូច ដែលគ្មានការប្រាក់និងជាពិសេសការរួមវិភាគទាន់ជាវិជ្ជមានរបស់ដៃគូរ ដូចជា សហគមន៏, អាជ្ញាធម៏ដែនដី, មណ្ឌលសុខភាព, ស្រុកប្រតិបត្តិ, មន្ទីរពេទ្យបង្អែក, អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នដ៏ទៃទៀត ដែលជាប់ពាក់ព័ន្ធ។ ការខកខានការឧបត្ថម្ភគាំទ្រចំនុចណាមួយខាងលើនេះមុខជានឹងធ្វើអោយមានអតុល្យភាពមកលើកម្រិតជីវភាពរស់របស់គាត់ដែលត្រឹមតែហូបឆ្អែតល្មមនាពេលបច្ចុប្បន្ននេះតែប៉ុណ្ណោះ។

# **លទ្ធផល**



Income Generation



Buying and Selling Vegetables

អ្នកស្រ **ផាន ផល** បាន ទទួលជម្រកថ្មីមួយពី អង្គការ **CSCN** តាមរយៈការគាំទ្រមូលនិធិពីអង្គការ **KHANA** និងការចូលរួមជួយសាងសង់ ពីប្រជាជន នៅក្នុង សហគមន៏ និង អាជ្ញាធរដែនដី ។ជម្រកថ្មីនេះ ជួយការពារគ្រួ សារអ្នកស្រីអោយផុត ពីការនៅហាល ភ្លៀង ហាលខ្យល់ ហាលថ្ងៃ និង អាកាសធាតុត្រ ជាក់ ហើយធ្វើអោយសុខភាពកាន់តែប្រសើរឡើង ក្រោយពីបានទទួលសេវាសុខភាពសមស្រប, ការឧបត្ថម្ភស្បៀង, ការគាំទ្រសុខមាលភាពសង្គម,



Buying/Selling fish



Doing home gardening

និង សំល្បៀកបំពាក់ និង សម្ភារៈសិក្សតាម
រយៈ អង្គការ **CSCN** ។ ក្រៅពីនេះការរក
ប្រាក់ចំណូលក៏ជាផ្នែកមួយនៃការអភិវឌ្ឍន
៍សេដ្ឋកិច្ចគ្រួសារ ។ អ្នកស្រី បានទទួល ៣0
ដុល្លរជាឥណទានខ្នាតតូច ដែលគ្មានការប្រា ក់ ។
អ្នកស្រីបានចំណាយមួយចំនួនទិញកង់
ជជុះមួយ ។ ជាមួយលុយសះសល់និងមធ្យោ
យថ្មី អ្នកស្រីបានចាប់ ផ្តើមរកស៊ីជួញដូរ តាម
ភូមិនា.៧.តាំងពីលក់ល្បៀសហាលរហូតដល់បន្លែ
និងត្រីគួប្សំនឹងប្រាក់ចំណូលបន្ថែមពីការស៊ីឈ្នួលេ
ធ្វីការងារ



Having enough food to eat



Going to school

តាមរដូវ ដូចជារដូវប្រាំង : ជ្រូតស្រូវតាម
ស្រែ និង ធ្វើស្មៅតាមចំការ និងរដូវវស្សា :
ដកស្ទូង។ អ្នកស្រីរកបានប្រាក់ចំណូលប្រចាំ
ថ្ងៃពីការងារមិនទៀងទាត់នេះ ពី៥០០០
រៀល ទៅ១០០០០រៀល ក្នុងមួយ ថ្ងៃ។
ដោយគំនិតឆ្នៃប្រឌិត និង ការឧប្ថម្ភគាំទ្រពី
អង្គការ **CSCN**  អ្នកស្រីអាចលៃអោយគ្រួ
សារហូបឆ្អែតល្មម និងអាចអោយកូនបាន
ទៅរៀននៅសាលា។

# **ការសន្និដ្ឋាន**

ការតាំងចិត្តរបស់អ្នកស្រី **ផាន ផល**, ការរួមវិភាគទានជាវិជ្ជានរបស់ដៃគូរទាំងអស់ និង ឧបត្ថម្ភគាំទ្រទាន់ពេលវេលាដោយអង្គការ **CSCN** តាមរយៈមូនិធិ **KHANA** និង ការផ្តល់ស្បៀងពីអង្គការស្បៀងអាហារពិភពលោក**WFP** គឺជាសមាសភាពដែលមិនអាចកាត់ផ្តាច់បាន ដើម្បីធ្វើអោយជីវភាពគ្រួសាររបស់អ្នកស្រីមកត្រឹមកម្រិតមួយដែលជិត និង ដល់ជិវភាពមួយដែលហួបឆ្អែតល្មម ។ *ដើម្បីឆ្លងអោយផុតពីកម្រិតនេះ ការបណ្តុះបណ្តាលអោយសមទៅនឹងសម្ថភាព និងលទ្ធភាពរបស់អ្នកស្រី និងសមាជិកគ្រួសាររបស់អ្នកស្រីជាពិសេសទៅលើការប្រកបមុខរបរចិញ្ចឹមជីវិតតាមគ្រួសារ ដោយប្រើប្រាស់ធនធានដែលមាននៅលើដីធ្លីរបស់គាត់ ជាប្រភពនៃចំណូលដែលអាចធ្វើទៅបានតាមលទ្ធភាព ត្រូវតែលើកយកមកពិចារណាមុនគេ ។*

***អរគុណ អ្នកសន្និសិទ្ធទាំងមូល ដែលបានយកចិត្តទុកដាក់ស្តាប់ !***